ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ទីស្តីការគណៈរដ្ឋមន្ត្រី
*Office of the Council Ministers*
លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
*Secretariat of the Task Force*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

# សេចក្តីប្រកាសព័ត៌មាន
# Press Release

## វិភាគទានរបស់រដ្ឋាភិបាលឥណ្ឌា ចំពោះចំណែកថវិកាកម្ពុជា សម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

ថ្ងៃនេះរដ្ឋាភិបាលឥណ្ឌា បានប្រកាសអំពីវិភាគទានចំនួន១លានដុល្លាសហរដ្ឋអាមេរិកចំពោះចំណែកថវិកាកម្ពុជាសម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមក្នុងពេលខាងមុខនេះ។

នៅព្រឹកថ្ងៃសុក្រនេះ ឯកឧត្តម **អាឡូក សេន** (Aloke Sen) ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា បានជំរាបជូនឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមអំពីវិភាគទាននេះ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាចំពោះវិភាគទានដ៏មានតំលៃនេះ។ ឯកឧត្តមបានមានប្រសាសន៍ថា "ប្រការនេះឆ្លុះបញ្ចាំងជាថ្មីម្តងទៀតអំពីចំណងមិត្តភាពរវាងរដ្ឋាភិបាលឥណ្ឌា និងរាជរដ្ឋាភិបាលកម្ពុជា ដែលមានលក្ខណៈឋិតថេរតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ននេះ។ ឥណ្ឌាគឺជាប្រទេសតែមួយគត់នៅក្រៅប្លុកសង្គមនិយមដែលមានស្ថានទូតនៅភ្នំពេញ និងគាំទ្រដល់ការស្តារកម្ពុជាឡើងវិញក្នុងស្ថានភាពដ៏លំបាកក្រោយថ្ងៃរំដោះពីរបបព្រៃផ្សៃរបស់ ប៉ុល ពត។ យើងនៅចងចាំនូវការជួយឧបត្ថម្ភរបស់អ្នកជំនាញការច្បាប់ឥណ្ឌានៅឆ្នាំ១៩៩៩ នៅពេលចាប់ផ្តើមធ្វើសេចក្តីព្រាងច្បាប់ស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញ។"

ឯកអគ្គរដ្ឋទូតឥណ្ឌាបានឆ្លើយតបថា "បើសិនយើងជាមិត្តដែលជួយគ្នាក្នុងគ្រាលំបាកនោះ គឺយើងជាមិត្តនឹងគ្នាជារៀងរហូត។" ឯកឧត្តមបានបន្តថាៈ រដ្ឋាភិបាលឥណ្ឌាបានសំរេចចិត្តផ្លាស់ប្តូរពីបំណងដំបូងរបស់ខ្លួនដែលថាផ្តល់វិភាគទានជាសំភារៈនោះ ព្រោះថាវិភាគទានជាទឹកប្រាក់ឆ្លើយតបប្រសើរជាងទៅនឹងតម្រូវការចាំបាច់របស់កម្ពុជាក្នុងការជួយបំពេញនូវកង្វះខាតថវិការបស់ខ្លួន។

ឯកឧត្តម **ស៊ាន វិសុទ្ធ** លេខាធិការប្រតិបត្តិនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល បានបញ្ជាក់ថា "យើងសូមស្វាគមន៍ចំពោះវិភាគទានដ៏មានតំលៃរបស់រដ្ឋាភិបាលឥណ្ឌា ហើយយើងសង្ឃឹមថាប្រទេសផ្សេងៗទៀត នឹងអនុវត្តតាមគំរូនេះដូចប្រទេសមួយចំនួនទៀតដែលពេលនេះកំពុងពិចារណាអំពីថវិកា និងទំរង់នៃវិភាគទានរបស់ខ្លួនដល់ចំណែកថវិការបស់កម្ពុជា។ ខ្ញុំសូមបញ្ជាក់ថា ចំណែកទាំងពីរក្នុងគំរោងថវិកានេះមានសារៈសំខាន់ដូចគ្នាក្នុងការរៀបចំដំណើរការអង្គជំនុំជម្រះក្តីមួយដែលប្រកបដោយស្តង់ដារអន្តរជាតិ។"

នៅពេលដែលថវិកាខាងភាគីអន្តរជាតិ (៤៣លានដុល្លា) មានស្ទើរតែគ្រប់ចំនួនកំណត់ហើយនោះ ភាគីកម្ពុជានៅកំពុងអំពាវនាវរកថវិកាជាជំនួយទ្វេភាគី ដើម្បីជួយបង្គ្រប់ការចំណាយក្នុងចំណែករបស់ខ្លួន ដែលមានចំនួន ១៣,៣លានដុល្លា។

រាជរដ្ឋាភិបាលកម្ពុជានឹងចូលរួមចំនួន ៦,៧លានដុល្លា (ក្នុងនោះ ១,៥លានជាសាច់ប្រាក់ និង ៥,២លានជាសំភារៈដែលមិនរាប់បញ្ចូលក្នុងគំរោងថវិកា)។ ការសន្យារបស់កម្ពុជានេះ មានចំនួនលើសពី១០%នៃចំណាយសរុបនៃអង្គជំនុំជម្រះវិសាមញ្ញទាំងមូល (៦១,៥លានដុល្លា - ៥៦,៣លានដុល្លា នៅក្នុងគំរោងថវិកា បូកនឹង ៥,២លានដុល្លា ក្រៅគំរោងថវិកា)។

ជាថ្មីម្តងទៀត យើងសូមអំពាវនាវចំពោះប្រទេសទាំងឡាយដែលស្នេហាយុត្តិធម៌ ដើម្បីជួយយើងបង្គ្រប់ចំណែកថវិកាដែលនៅខ្វះដើម្បីអោយអង្គជំនុំជម្រះវិសាមញ្ញ អាចចាប់ផ្តើមដំណើរការក្នុងពេលដ៏ឆាប់ខាងមុខនេះ ហើយប្រកបដោយស្តង់ដារអន្តជាតិដែលយើងបានព្រមព្រៀងទាំងអស់គ្នា ដើម្បីផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជា និងមនុស្សជាតិទាំងមូល។

រាជធានីភ្នំពេញ, ថ្ងៃទី ៧ តុលា ២០០៥